# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## របៀបរបប និង ការរៀបចំការបោះឆ្នោតសភាពាណិជ្ជកម្ម

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៣ ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើ ច្បាប់ ស្តីពីសភាពាណិជ្ជកម្ម
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## *សម្រេច*

## ជំពូកទី ១

### បទប្បញ្ញត្តិទូទៅ

**មាត្រា ១ :**

សភាពាណិជ្ជកម្ម មានសមាជិកជ្រើសតាំងតាមការបោះឆ្នោត និង សមាជិកទីប្រឹក្សា ។ [illegible]

សមាជិកជ្រើសតាំងតាមការបោះឆ្នោត ត្រូវបានកំណត់ដោយអនុក្រឹត្យបង្កើតសភាពាណិជ្ជកម្មនីមួយៗ ហើយចំនួនសមាជិកទីប្រឹក្សា ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងពាណិជ្ជកម្ម ។

អាណត្តិរបស់សមាជិកសភាពាណិជ្ជកម្មមានរយៈពេល ០៦ ឆ្នាំ ។ រៀងរាល់ ០៣ឆ្នាំម្តង សភាពាណិជ្ជកម្មត្រូវរៀបចំការបោះឆ្នោតជ្រើសរើសសមាជិកជ្រើសតាំងថ្មីចំនួនពាក់កណ្តាល លើកលែងតែនៅក្នុងអាណត្តិដំបូង ត្រូវមានការចាប់ឆ្នោតជ្រើសរើសសមាជិកចំនួនពាក់កណ្តាល ដែលត្រូវបញ្ចប់អាណត្តិ ក្រោយរយៈពេល ០៣ ឆ្នាំ ។

**មាត្រា ២ :**

សមាជិកជ្រើសតាំងនៃសភាពាណិជ្ជកម្ម ត្រូវចូលបំពេញការងាររបស់ខ្លួនក្រោយថ្ងៃប្រកាសលទ្ធផលបោះឆ្នោតយ៉ាងយូរមួយខែ ក្រោមអធិបតីភាពរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ឬតំណាង និងអភិបាលខេត្ត-ក្រុង ឬតំណាងនៃមណ្ឌលរបស់សាមីសភាពាណិជ្ជកម្ម ។

**មាត្រា ៣ :**

ក្នុងករណីដែលចំនួនសមាជិកជ្រើសតាំងធ្លាក់មកនៅទាបជាងពាក់កណ្តាល សភាពាណិជ្ជកម្មត្រូវបានរំសាយ ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។ ការជ្រើសតាំងសមាជិកជាថ្មីត្រូវធ្វើក្នុងរយៈពេល ០៣ខែយ៉ាងយូរ គិតពីថ្ងៃចេញអនុក្រឹត្យ ។

ក្រសួងពាណិជ្ជកម្មត្រូវប្រកាសតែងតាំងគណៈកម្មការបណ្តោះអាសន្នមួយ ដើម្បីដឹកនាំសភាពាណិជ្ជកម្មជាបន្ទាន់ ។

## ជំពូកទី ២

## គណៈកម្មការរៀបចំការបោះឆ្នោត

**មាត្រា ៤ :**

ក/- គណៈកម្មការរៀបចំការបោះឆ្នោតជ្រើសរើសសមាជិកជ្រើសតាំងសភាពាណិជ្ជកម្ម អាណត្តិទី ១ មានសមាសភាពដូចខាងក្រោម :

- តំណាងក្រសួងពាណិជ្ជកម្ម ប្រធាន
- តំណាងក្រុមប្រឹក្សាអ្នកច្បាប់ អនុប្រធាន
- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី
- តំណាងក្រសួងមហាផ្ទៃ
- តំណាងសាលាខេត្ត-ក្រុង សាមី

- តំណាងក្រសួងទេសចរណ៍ សមាជិក
- តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក
- តំណាងធនាគារជាតិនៃកម្ពុជា សមាជិក
- តំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សមាជិក
- តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក
- តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក
- តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក
- តំណាងក្រសួងអប់រំ យុវជន និងកីឡា សមាជិក
- តំណាងក្រសួងយុត្តិធម៌ សមាជិក
- មន្ត្រីក្រសួងពាណិជ្ជកម្ម ០២រូប លេខាធិការ

ខ/-គណៈកម្មការរៀបចំការបោះឆ្នោតជ្រើសរើសសមាជិកជ្រើសតាំងសភាពាណិជ្ជកម្ម អាណត្តិបន្តបន្ទាប់ មានសមាសភាពដូចខាងក្រោម :

- តំណាងក្រសួងពាណិជ្ជកម្ម ប្រធាន
- តំណាងសាមីសភាពាណិជ្ជកម្ម អនុប្រធាន
- តំណាងក្រសួងមហាផ្ទៃ សមាជិក
- តំណាងសាលា ខេត្ត-ក្រុង សាមី សមាជិក
- អគ្គនាយកសាមីសភាពាណិជ្ជកម្ម លេខាធិការ

**<u>មាត្រា ៥</u> :**

គណៈកម្មការរៀបចំការបោះឆ្នោត មានភារកិច្ចដូចតទៅ :

- ណែនាំលំអិត ស្តីពីបែបបទបោះឆ្នោត ដល់សាធារណជន
- ធ្វើបញ្ជីអ្នកមានសិទ្ធិបោះឆ្នោតតាមប្រភេទអាជីវកម្មនីមួយៗ ប្រភេទពាណិជ្ជកម្ម ប្រភេទឧស្សាហកម្ម និងសិប្បកម្ម ប្រភេទសេវាកម្មនិងវិជ្ជាជីវៈសេរី ប្រភេទកសិកម្ម ។ បញ្ជីនេះត្រូវចុះហត្ថលេខាបញ្ជាក់ដោយរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។
- ធ្វើប័ណ្ណគ្រប់ជំពូកសំរាប់ការបោះឆ្នោត
- ធ្វើបញ្ជីបេក្ខជនឈរឈ្មោះ ជាសមាជិកជ្រើសតាំងរបស់សភាពាណិជ្ជកម្ម ។ បញ្ជីនេះត្រូវចុះហត្ថលេខាបញ្ជាក់ដោយរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។
- ចាត់វាលវិធានការណ៍សំរាប់ត្រួតពិនិត្យមើលការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។
- រៀបចំការិយាល័យបោះឆ្នោត ។



ЧК

- ដើម្បីបំពេញកាតព្វកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធិភាព គណៈកម្មការរៀបចំការបោះឆ្នោត មានសិទ្ធិលប់ឈ្មោះបេក្ខជនណាមួយ ចេញពីបញ្ជីបេក្ខជន ក្នុងករណីដែលសាមីខ្លួនមិនគោរពបែបបទ និងការណែនាំរបស់គណៈកម្មការក្នុងការបោះឆ្នោត ។

**មាត្រា ៦ :**

ក្រសួងពាណិជ្ជកម្ម ត្រូវធ្វើការកំណត់ទីតាំងរបស់គណៈកម្មការសំរាប់ការបោះឆ្នោតនៅអាណត្តិទី ១ ។ ចំពោះការបោះឆ្នោតសំរាប់អាណត្តិបន្តបន្ទាប់ទៀត ទីតាំងសំរាប់គណៈកម្មការនេះត្រូវកំណត់ដោយសាមីសភាពាណិជ្ជកម្ម ។

សមាជិកគណៈកម្មការ ត្រូវចូលរួមប្រជុំ និងបំពេញការងារតាមការកំណត់របស់ប្រធាន ។

សេចក្តីសំរេចរបស់គណៈកម្មការ នឹងមានសុពលភាពបាន លុះណាតែមានសមាជិកចំនួនពាក់កណ្តាលយ៉ាងតិចមកចូលរួមប្រជុំ ។

**មាត្រា ៧ :**

រាល់ការចំណាយរបស់គណៈកម្មការក្នុងការរៀបចំបោះឆ្នោតនៅអាណត្តិទី ១នេះ ជាបន្ទុករបស់ថវិការដ្ឋ ។ ការចំណាយសំរាប់ការបោះឆ្នោតនៅអាណត្តិបន្តបន្ទាប់ទៀត ជាបន្ទុករបស់សាមីសភាពាណិជ្ជកម្ម ។

# ជំពូកទី ៣

## ការបោះឆ្នោត

**មាត្រា ៨ ;**

ក/- អ្នកមានសិទ្ធបោះឆ្នោតជ្រើសតាំងសភាពាណិជ្ជកម្មអាណត្តិទី ១ ត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម :

១- មានសញ្ជាតិជាខ្មែរ

២- មានអាយុយ៉ាងតិច ១៨ ឆ្នាំ

៣- ជាពាណិជ្ជករ ឧស្សាហករ សិប្បករ អ្នកធ្វើសេវាកម្មទេសចរណ៍ អ្នកធ្វើអាជីវកម្មកសិកម្ម អ្នកធ្វើសេវាកម្មផ្សេងៗទៀត សហគ្រាស និងក្រុមហ៊ុននានាដែលបានចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម ឬបានទទួលការអនុញ្ញាតពីក្រសួង ស្ថាប័នមានសមត្ថកិច្ចណាមួយឱ្យធ្វើអាជីវកម្ម ហើយដែលមានទីស្នាក់ការ ឬអាគារធ្វើអាជីវកម្មនៅតាមខេត្ត-ក្រុង សាមី ។

ខ/- អ្នកមានសិទ្ធិបោះឆ្នោតជ្រើសតាំងសភាពាណិជ្ជកម្មអាណត្តិបន្តបន្ទាប់ទៀត ត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម :

៤- មានសញ្ជាតិជាខ្មែរ

៥- មានអាយុយ៉ាងតិច ១៨ ឆ្នាំ

៦- ជាសមាជិករបស់សាមីសភាពាណិជ្ជកម្ម

## <u>មាត្រា ៩</u> :

អ្នកមានសិទ្ធិបោះឆ្នោត ត្រូវសុំចុះឈ្មោះបោះឆ្នោត នៅក្នុងបញ្ជីអ្នកបោះឆ្នោតរបស់គណៈកម្មការរៀបចំការបោះឆ្នោត តាមការកំណត់របស់គណៈកម្មការនេះ ។

នៅក្រោយពេលបញ្ឈប់ការចុះឈ្មោះ បញ្ជីអ្នកបោះឆ្នោតត្រូវបិទផ្សាយនៅក្រសួងពាណិជ្ជកម្ម និងនៅសាលាខេត្ត-ក្រុង ។

ក្នុងករណីមានការតវ៉ា រាល់អ្នកមានសិទ្ធិបោះឆ្នោតអាចប្តឹងតវ៉ាមកគណៈកម្មការ ក្នុងរយៈពេល ១៥ថ្ងៃយ៉ាងយូរ គិតពីថ្ងៃដែលបានបិទផ្សាយបញ្ជី ។

ហួសពីរយៈពេលនេះ គណៈកម្មការបោះឆ្នោតបញ្ចប់បញ្ជីជាស្ថាពរ ។ រាល់ការតវ៉ាត្រូវឈប់ទទួល ។

## <u>មាត្រា ១០</u> :

ក/- បេក្ខជនសមាជិកជ្រើសតាំងសភាពាណិជ្ជកម្មអាណត្តិទី ១ ត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម :

១- បានចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតរួចហើយ

២- មានអាយុយ៉ាងតិច ៣០ឆ្នាំ

៣- បានបង់ថ្លៃសិទ្ធិឈរឈ្មោះបោះឆ្នោតតាមការកំណត់របស់គណៈកម្មការបោះឆ្នោត

៤- មិនបានប្រាសចាកសិទ្ធិខាងរដ្ឋប្បវេណី សិទ្ធិពលរដ្ឋ និងសិទ្ធិខាងនយោបាយ ។

ខ/- បេក្ខជនសមាជិកជ្រើសតាំងសភាពាណិជ្ជកម្មអាណត្តិបន្តបន្ទាប់ទៀត ត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម :

១- បានចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតរួចហើយ

២- ជាសមាជិករបស់សាមីសភាពាណិជ្ជកម្ម និងជាក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម នៅក្រសួងពាណិជ្ជកម្ម និងបានបំពេញកាតព្វកិច្ចបង់ពន្ធជូនរដ្ឋត្រឹមត្រូវនៅឆ្នាំអាជីវកម្មកន្លងមក

៣- មានអាយុយ៉ាងតិច ៣០ ឆ្នាំ

៤- បានបង់ថ្លៃសិទ្ធិឈរឈ្មោះបោះឆ្នោត តាមការកំណត់របស់គណៈកម្មការបោះឆ្នោត

៥- មិនបានប្រាសចាកសិទ្ធិខាងរដ្ឋប្បវេណី សិទ្ធិពលរដ្ឋ និងសិទ្ធិខាងនយោបាយ ។

**មាត្រា ១១ :**

បេក្ខជនដែលចង់ឈរឈ្មោះជាសមាជិកជ្រើសតាំង ត្រូវសុំចុះឈ្មោះជាបេក្ខជនក្នុងបញ្ជីបេក្ខជន របស់គណៈកម្មការរៀបចំការបោះឆ្នោត តាមការកំណត់របស់គណៈកម្មការនេះ ។ ការសុំចុះឈ្មោះនេះ ត្រូវធ្វើដោយសាមីបេក្ខជនផ្ទាល់ និង ចុះហត្ថលេខាដោយផ្ទាល់ដៃលើសំណុំបែបបទផ្សេងៗ ។

បញ្ជីបណ្តោះអាសន្ននៃបេក្ខជន ត្រូវបញ្ឈប់ ១៥ថ្ងៃ មុនថ្ងៃបោះឆ្នោត ។ បញ្ជីនេះត្រូវបិទផ្សាយនៅក្រសួងពាណិជ្ជកម្ម និង នៅសាលាខេត្ត-ក្រុង ។

យ៉ាងយូរ ០៧ថ្ងៃ មុនថ្ងៃបោះឆ្នោត បេក្ខជនមានសិទ្ធិតវ៉ាទៅរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម អំពី ការរាំងមិនអោយខ្លួនចុះឈ្មោះ ឬភ្លេចចុះឈ្មោះខ្លួននៅក្នុងបញ្ជីនេះ ។

បញ្ជីបេក្ខជនជាស្ថាពរត្រូវបញ្ចប់ ០៧ ថ្ងៃ មុនពេលបោះឆ្នោត ។ ចាប់ពីថ្ងៃបញ្ចប់តទៅមិនអនុញ្ញាតិឱ្យធ្វើការតវ៉ាទេ ។ បញ្ជីស្ថាពរនេះត្រូវបិទផ្សាយនៅទីកន្លែងដែលបានបិទផ្សាយបញ្ជីបណ្តោះអាសន្ន ។

**មាត្រា ១២ :**

ការបោះឆ្នោតមានដំណើរប្រព្រឹត្តទៅដូចខាងក្រោម :

១- ការបោះឆ្នោតជ្រើសរើសសមាជិកជ្រើសតាំងរបស់សភាពាណិជ្ជកម្ម ត្រូវបានអនុវត្តតាមគោលការណ៍ :

- យកសំលេងភាគច្រើន
- បោះឆ្នោតតាមឈ្មោះនីមួយៗ
- បោះឆ្នោតតែមួយជុំ

ក្នុងករណីដែលមានបេក្ខជនច្រើននាក់ទទួលសំលេងស្មើគ្នានោះ ត្រូវជ្រើសតាំងបេក្ខជនដែលមានអាយុច្រើនជាង ។

២- ការិយាល័យបោះឆ្នោតត្រូវបានរៀបចំតែមួយកន្លែង ហើយរយៈពេលបោះឆ្នោតត្រូវកំណត់តែមួយថ្ងៃ គឺចាប់ពីម៉ោង ៨:០០ ព្រឹក ដល់ម៉ោង ១៥:០០ ល្ងាច ។

៣- ការឃោសនាបោះឆ្នោតជាសាធារណៈ ត្រូវកំណត់ចាប់ផ្តើម ១៥ថ្ងៃ មុនថ្ងៃបោះឆ្នោតតាមប្រតិទិនរបស់គណៈកម្មការរៀបចំការបោះឆ្នោត ហើយត្រូវបញ្ចប់ ៣ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

៤- អ្នកបោះឆ្នោត ត្រូវយកប័ណ្ណបោះឆ្នោតមកជាមួយសំរាប់ដូរយកសន្លឹកឆ្នោត ។ អ្នកបោះឆ្នោតត្រូវមកបោះឆ្នោតដោយផ្ទាល់ ។ ប្រសិនបើមានការបាត់បង់ប័ណ្ណបោះឆ្នោត អ្នកបោះឆ្នោតត្រូវប្រកាសប្រាប់គណៈកម្មការរៀបចំការបោះឆ្នោតជាលាយលក្ខណ៍អក្សរ ១ថ្ងៃ មុនថ្ងៃបោះឆ្នោត ដើម្បីសុំប្តូរយកប័ណ្ណបោះឆ្នោតថ្មី ។

៥- បេក្ខជននីមួយៗមានសិទ្ធិចាត់តាំងតំណាងម្នាក់ អោយចូលសង្កេតការណ៍ក្នុងកិច្ចដំណើរការនៃការបោះឆ្នោតជាមួយគណៈកម្មការ ។

៦- គណៈកម្មការបោះឆ្នោត ត្រូវអញ្ជើញក្រសួង ស្ថាប័នពាក់ព័ន្ធ មួយចំនួនអោយចូលរួមធ្វើជាអ្នកសង្កេតការណ៍ ។

៧- ការរាប់សន្លឹកឆ្នោតត្រូវរាប់អោយចប់នៅថ្ងៃបោះឆ្នោត ហើយយោងតាមកំណត់ហេតុនៃគណៈកម្មការបោះឆ្នោត រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មត្រូវប្រកាសលទ្ធផលនៃការបោះឆ្នោតនៅថ្ងៃដដែល។ លទ្ធផលនេះត្រូវចាត់ទុកជាស្ថាពរ ពុំអាចត្រូវបានតវ៉ានៅចំពោះមុខអង្គការណាបានឡើយ ។ ការទទួលស្គាល់សមាជិកជ្រើសតាំងរបស់សភាពាណិជ្ជកម្ម ត្រូវធ្វើឡើងដោយអនុក្រឹត្យ ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

### មាត្រា ១៣ :

អនុក្រឹត្យលេខ ៦៣អនក្រ.បក ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ១៩៩៥ ស្តីពីរបៀបរបប និងការរៀបចំការបោះឆ្នោតសភាពាណិជ្ជកម្ម និងបទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

### មាត្រា ១៤ :

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័ន អភិបាលខេត្ត-ក្រុងពាក់ព័ន្ធ និងសភាពាណិជ្ជកម្ម ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ.ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១៤
- ឯកសារ-កាលប្បវត្តិ